# លិខិតរបស់

## លោកយូដាស

### ពាក្យនាំ

អ្នកតែងលិខិតនេះសរសេរថា គាត់ត្រូវជាប្អូនរបស់លោកយ៉ាកុប[១] និងត្រូវជាបងប្អូនរបស់ព្រះយេស៊ូជាអម្ចាស់ដែរ (ម៉ាថាយ១៣.៥៥ កាឡាទី ១.១៩)។ លោកយូដាសសរសេរលិខិតនេះសម្រាប់គ្រីស្តបរិស័ទទូទៅ ហើយមានសេចក្ដីប្រហាក់ប្រហែលគ្នានឹងលិខិតទីពីររបស់លោកសិលាដែរ។

### គោលបំណង

អ្នកតែងមានបំណងប្រៀនប្រដៅគ្រីស្តបរិស័ទ ឲ្យប្រយ័ត្នខ្លួន កុំស្ដាប់គ្រូអាចារ្យក្លែងក្លាយដែលផ្សាយលទ្ធិផ្ដេសផ្ដាស។ លោកប្រៀនប្រដៅឲ្យកាន់ជាប់តាមសេចក្ដីប្រៀនប្រដៅ ដែលអស់លោកគ្រីស្តទូតបានបង្រៀនទុកមក(៣)។

សេចក្ដីពន្យល់របស់លោកយូដាសពិបាកស្ដាប់បន្តិច ព្រោះលោកពន្យល់តាមរបៀបជនជាតិយូដា នៅសម័យនោះ។

### គម្រោងក័ណ្ឌគម្ពីរយូដាស៖

- សេចក្ដីផ្ដើម ១-៣។
- ចរិតមារយាទ សេចក្ដីបង្រៀន និងទោសរបស់គ្រូក្លែងក្លាយ ៣-១៦។
- ពាក្យដាស់តឿនឲ្យនៅជាប់នឹងជំនឿ ១៧-២៣។
- ពាក្យជូនពរ ២៤-២៥។

# លិខិតរបស់លោកយូដាស

## សេចក្ដីផ្ដើម

១ខ្ញុំយូដាស ជាអ្នកបម្រើរបស់ព្រះយេស៊ូគ្រី
ស្ដ* និងជាប្អូនរបស់លោកយ៉ាកុប សូមជម្រាប
មកបងប្អូនដែលព្រះជាម្ចាស់ជាព្រះបិតាបាន
ត្រាស់ហៅ គឺអ្នកដែលព្រះអង្គស្រឡាញ់ហើយ
បម្រុងទុក សម្រាប់ព្រះយេស៊ូគ្រីស្ដសូមជ្រាប។

២សូមព្រះជាម្ចាស់មេត្ដា ករុណា ប្រទាន
សេចក្ដីសុខសាន្ដ និងសេចក្ដីស្រឡាញ់ដល់បង
ប្អូនយ៉ាងបរិបូណ៌។

## អំពីគ្រូអាចារ្យក្លែងក្លាយ

៣បងប្អូនជាទីស្រឡាញ់ ខ្ញុំមានបំណងចង់
សរសេរមកបងប្អូនអំពីការសង្គ្រោះដែលយើង
បានទទួលរួមគ្នានោះខ្លាំងណាស់ ហើយក៏មាន
មូលហេតុបង្ខំខ្ញុំឲ្យសរសេរលិខិតនេះ មកដាស់
តឿនបងប្អូនឲ្យតយុទ្ធការពារជំនឿ ដែលព្រះជា
ម្ចាស់បានប្រទានដល់ប្រជាជនដ៏វិសុទ្ធ* ម្ដងជា
សូរេច ៤ដ្បិតមានអ្នកខ្លះបានបន្លំខ្លួនចូលមក
ក្នុងចំណោមបងប្អូន ពួកគេជាមនុស្សមិនគោរព
ប្រណិប័តន៍ព្រះជាម្ចាស់ គេបានបង្ខូចការប្រណី
សន្ដោសរបស់ព្រះនៃយើង ឲ្យក្លាយទៅជារឿង
អាសអាភាស ហើយបដិសេធមិនព្រមទទួល
ស្គាល់ព្រះយេស៊ូគ្រីស្ដ* ជាចៅហ្វាយ និងជា
ព្រះអម្ចាស់តែមួយគត់របស់យើងដែរ។អ្នកទាំង
នោះនឹងទទួលទោសដូចមានចែងទុកជាមុន
តាំងពីយូរយារណាស់មកហើយ។

៥បងប្អូនបានជ្រាបសេចក្ដីទាំងនេះរួច
ស្រេចហើយ តែខ្ញុំចង់រំលឹកបងប្អូនថា ក្រោយ
ពេលដែលព្រះអម្ចាស់បានសង្គ្រោះប្រជារាស្ដ្រ
អ៊ីស្រាអែល ឲ្យចេញផុតពីប្រទេសអេស៊ីបមក
ព្រះអង្គបានធ្វើឲ្យអ្នកមិនព្រមជឿ ត្រូវវិនាស
អន្ដរាយ។៦រីឯពួកទេវទូត* ដែលពុំបានរក្សាឋា
នៈរបស់ខ្លួន តែបែរជាបោះបង់ចោលលំនៅ
របស់ខ្លួនផ្ទាល់ទៅវិញនោះ ព្រះជាម្ចាស់បានឃុំ
គេទុកក្នុងទីងងឹត ហើយគេនៅជាប់ចំណងអស់
កល្បជានិច្ចរង់ចាំថ្ងៃដ៏អស្ចារ្យ ដែលព្រះជាម្ចាស់
នឹងវិនិច្ឆ័យទោស។ ៧រីឯក្រុងសូដុម ក្រុងកូម៉ូរ៉ា
និងក្រុងឯទៀតៗដែលនៅជិតខាងក៏ដូច្នោះដែរ
ពួកអ្នកក្រុងបាននាំគ្នាប្រព្រឹត្ត អំពើប្រាសចាក
សីលធម៌ ដូចទេវទូតទាំងនោះ គឺកាត់រករួម
បវេណី ផ្ទុយពីធម្មជាតិ។ ពួកគេបានទទួល
ទណ្ឌកម្ម នៅក្នុងភ្លើងដែលឆេះអស់កល្បជានិច្ច
ទុកជាការព្រមានដល់អ្នកឯទៀតៗ។

៨ពួកទាំងនេះក៏ប្រព្រឹត្តដូច្នោះដែរ គំនិតរវើ
រវាយរបស់គេ បានធ្វើឲ្យរូបកាយខ្លួនទៅជា
សៅហ្មងគេមើលងាយអំណាចរបស់ព្រះអម្ចាស់
និងជេរប្រមាថពួកទេវតា ដែលប្រកបដោយសិរី
រុងរឿង[ក]។ ៩នៅពេលមហាទេវតាមីកាអែល
ប្រកែកជាមួយនឹងមារ*តវ៉ាអំពីសពរបស់លោក
ម៉ូសេនោះលោកក៏ពុំហ៊ានដាក់ទោសវា ដោយ
ជេរប្រមាថឡើយ គឺលោកគ្រាន់តែពោលថា«
សូមព្រះអម្ចាស់ដាក់ទោសឯង!»[ខ]។ ១០រីឯអ្នក
ទាំងនោះវិញ គេនាំគ្នាជេរប្រមាថអ្វីៗដែលខ្លួនពុំ
ស្គាល់ ហើយអ្វីៗដែលគេស្គាល់តាមសភាវគតិ
ដូចសត្វតិរច្ឆានបណ្ដាលឲ្យតែខ្លួនគេត្រូវវិនាស
ប៉ុណ្ណោះ។ ១១អ្នកទាំងនោះត្រូវវេទនាជាពុំខាន
ដ្បិតគេបានដើរតាមផ្លូវរបស់លោកកាអ៊ីន[គ]។

ពួកគេបានបណ្ដោយខ្លួនឲ្យវង្វេង ដូចលោកបាឡាម[យ]ព្រោះតែចង់បានប្រាក់ ពួកគេក៏វិនាសអន្តរាយព្រោះតែការបះបោរ ដូចលោកកូរេដែរ[ង]។

១២នៅពេល ដែលបងប្អូនបរិភោគអាហាររួមគ្នា ដោយចិត្តស្រឡាញ់ អ្នកទាំងនោះបានធ្វើឲ្យមានល្អក់កករ គឺគេនាំគ្នាស៊ីផឹកបំពេញក្រពះឥតអៀនខ្មាសទាល់តែសោះ។ ពួកគេប្រៀបបានទៅនឹងពពកឥតមានភ្លៀង ដែលរសាត់តាមខ្យល់ ប្រៀបបាននឹងដើមឈើគ្មានផ្លែក្នុងរដូវផ្លែ ហើយជាដើមឈើរលើងឫស ដែលងាប់ពីរដងទៅហើយ ១៣ពួកគេប្រៀបបីដូចជារលកសមុទ្រដ៏កំណាចបក់បោកបែកពពុះ គួរឲ្យអៀនខ្លួន។ ពួកគេប្រៀបបានទៅនឹងផ្កាយវង្វេងទិស ដែលព្រះជាម្ចាស់បម្រុងទុក ឲ្យស្ថិតនៅក្នុងទីងងឹតសូន្យសុងអស់កល្បជានិច្ច!

១៤លោកហេណុក ដែលជាបុព្វបុរសតំណទីប្រាំពីរ ក្រោយលោកអដាំបានថ្លែងទុកអំពីអ្នកទាំងនោះដូចតទៅ៖ «មើល!ព្រះអម្ចាស់យាងមកជាមួយប្រជាជនដ៏វិសុទ្ធ* របស់ព្រះអង្គដែលមានចំនួនដ៏ច្រើនអនេកអនន្ត ១៥ដើម្បីវិនិច្ឆ័យទោសមនុស្សទូទៅនិងបង្ហាញឲ្យមនុស្សទាំងអស់ ដែលមិនគោរពប្រណិប័តន៍ព្រះជាម្ចាស់ដឹងកំហុសរបស់ខ្លួន ហើយឲ្យអ្នកបាបទាំងនោះដឹងអំពីពាក្យសំដីទាំងប៉ុន្មាន ដែលគេបានពោលប្រឆាំងនឹងព្រះអង្គ»[ច]។ ១៦ពួកគេជាមនុស្សរអ៊ូរទាំ មិនដែលសប្បាយចិត្តសោះ គេប្រព្រឹត្តតាមចិត្តលោភលន់របស់ខ្លួន។ ពាក្យសំដីរបស់គេចេញមក សុទ្ធតែជាពាក្យអួតដ៏សម្បើម ហើយគេតែងតែបញ្ជើចបញ្ជើអ្នកដទៃ ដើម្បីរកប្រយោជន៍ផ្ទាល់ខ្លួន។

## ពាក្យដាស់តឿនផ្សេងៗ

១៧ចំពោះបងប្អូនវិញ បងប្អូនជាទីស្រឡាញ់អើយ ចូរនឹកចាំសេចក្ដីប្រៀនប្រដៅដែលក្រុមគ្រីស្ដទូត*របស់ព្រះយេស៊ូគ្រីស្ដ ជាអម្ចាស់នៃយើងបានប្រាប់បងប្អូនកាលពីមុន។ ១៨លោកទាំងនោះមានប្រសាសន៍ប្រាប់បងប្អូនថា «នៅគ្រាចុងក្រោយបំផុត នឹងមានពួកអ្នកចំអកមើលងាយ ពួកគេជាមនុស្សមិនគោរពប្រណិប័តន៍ព្រះជាម្ចាស់ ហើយប្រព្រឹត្តតាមចិត្តលោភលន់របស់ខ្លួន»។ ១៩អ្នកទាំងនោះជាមេបង្កឲ្យមានការបាក់បែកគ្នា ជាមនុស្សដែលមានគំនិតលោកីយ៍ ហើយគ្មានព្រះវិញ្ញាណគង់ជាមួយទេ។

២០រីឯបងប្អូនវិញបងប្អូនជាទីស្រឡាញ់អើយចូរកសាងគ្នាទៅវិញទៅមក លើជំនឿដ៏វិសុទ្ធបំផុតរបស់បងប្អូន ចូរអធិស្ឋានតាមព្រះវិញ្ញាណដ៏វិសុទ្ធ។ ២១ចូរស្ថិតនៅជាប់នឹងសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ទាំងទន្ទឹងរង់ចាំព្រះហឫទ័យមេត្តាករុណារបស់ព្រះយេស៊ូគ្រីស្ដជាព្រះអម្ចាស់នៃយើង ដើម្បីទទួលជីវិតអស់កល្បជានិច្ចផង។ ២២ត្រូវមេត្តាករុណាដល់បងប្អូនណាដែលមានចិត្តស្ទាក់ស្ទើរ ២៣ត្រូវសង្គ្រោះគេ ដោយអូសទាញគេ ឲ្យរួចផុតពីភ្លើង។ ចំពោះអ្នកឯទៀតៗវិញ ត្រូវមេត្តាករុណាដល់គេដែរ តែត្រូវភ័យខ្លាច គឺសូម្បីតែអាវដែលប៉ះនឹងរូបកាយគេ ក៏សៅហ្មងដែរ កុំប៉ះពាល់ឲ្យ

សោះ។
២៤ព្រះជាម្ចាស់អាចការពារបងប្អូន មិនឲ្យ
មានកំហុស ព្រមទាំងឲ្យឈរនៅមុខសិរីរុងរឿង
របស់ព្រះអង្គ ឥតសៅហ្មងនិងមានអំណរ
សប្បាយទៀតផង។
២៥មានព្រះជាម្ចាស់តែមួយព្រះអង្គទេ ដែល
ជាព្រះសង្គ្រោះយើង ដោយសារព្រះយេស៊ូគ្រី
ស្ដ ជាព្រះអម្ចាស់នៃយើង។ សូមលើកតម្កើង
សិរីរុងរឿងបារមីឧត្ដុង្គឧត្ដម ព្រះចេស្ដានិង
អំណាច ដែលទ្រង់មានតាំងពីមុនកាលសម័យ
ទាំងអស់ ហើយទ្រង់ក៏មាននៅពេលនេះ និង
អស់កល្បតរៀងទៅ។ អាម៉ែន!។

*ក. ពាក្យដើម «សិរីរុងរឿងនានា»(សូមអាន២ សិលា២.១០-១១ដែរ)។*

*ខ.សាការី ៣.២។ គម្ពីរសម្ព័ន្ធមេត្រីចាស់ពុំបានថ្លែងអំពីជម្លោះរវាងមហាទេវទូតមីកាអែលនិងមារ* នេះទេ ប៉ុន្តែប្រហែលជាមានសរសេរនៅក្នុងសៀវភៅមួយរបស់ជនជាតិយូដាដែលនិយាយអំពីលោកម៉ូសេឡើងទៅស្ថានសួគ៌។ •គ. កំណើតពិភពលោក/ លោកុប្បត្តិ៤.៨។•ឃ. ជនគណនា២២។•ង. ជនគណនា១៦។•ច.ដកស្រង់ចេញពីសៀវភៅហេណុក១.៩។ សៀវភៅហេណូកមិនបានរាប់បញ្ចូលក្នុងព្រះគម្ពីរទេ។*